01298256

E319/42/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 21 / 06 / 2016
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យទទួលយកជាឯកសារភស្តុតាងនូវឯកសារ E319/42.3.1, E319/42.3.2 និង ឯកសារមួយជាមូលដ្ឋាននៃបញ្ជីឈ្មោះអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយដែលបានដាក់នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ ដោយសហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកឯកសារចំនួនបីធ្វើជាឯកសារភស្តុតាង (ឯកសារ E319/42/2 កថាខណ្ឌ ១ និង ៤)។ ឯកសារចំនួនពីរក្នុងចំណោមឯកសារទាំងនេះគឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សី (ឯកសារ E319/42.3.1 និង E319/42.3.2) ដែលមានចម្លើយពីមុនៗរបស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច (2-TCW-916) ដែលកំពុងផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងមន្ទីរសន្តិសុខ ស-២១ នៅក្នុងសំណុំរឿង ០០២/០២។ ឯកសារទីបី (ឯកសារ E319/42/2.1) គឺជាចម្លើយសារភាពរបស់ ចិន សួន ដែលការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) យកមកសំអាង ក្នុងការចងក្រងបញ្ជីឈ្មោះអ្នកជាប់ឃុំនៅ

មន្ទីរសន្តិសុខ ស-២១ ដែលត្រូវបានធ្វើបច្ចុប្បន្នភាព (ឯកសារ E393.2) តែមិនត្រូវបានបញ្ចូលទៅក្នុងបញ្ជីឯកសារជាមូលដ្ឋានចុងក្រោយ ដែលត្រូវបានទទួលយកធ្វើជាឯកសារភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E393.3)នោះទេ។ នៅក្នុងសវនាការថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកឯកសារ E319/42.3.1 ជាឯកសារភស្តុតាងដោយសំអាងហេតុនឹងចេញនៅពេលក្រោយ (សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦ ទំព័រ២៤)។ អង្គជំនុំជម្រះសាលាដំបូងនាពេលនេះ សូមផ្តល់សំអាងហេតុនៃការទទួលយកឯកសារនេះ និងសម្រេចទៅលើសំណើសុំដែលនៅសេសសល់ដូចខាងក្រោម។

២. អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកឡើងវិញ អំពីការអនុវត្តរបស់ខ្លួនចំពោះការទទួលយកធ្វើជាឯកសារភស្តុតាងនូវចម្លើយពីមុនៗរបស់សាក្សី ដែលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង (*សូមមើល* ឧទាហរណ៍ ឯកសារ E319/36/2 កថាខណ្ឌ ១៥ ឯកសារ E363/3 កថាខណ្ឌ ២៥)។ វាជាប្រយោជន៍ក្នុងការស្វែងរកការពិត ដែលអង្គជំនុំជម្រះ និង ភាគីមានលទ្ធភាពពិនិត្យមើលចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលនឹងត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២។ លើសពីនេះទៀត ឯកសារទាំងនេះគួរត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីអាចឱ្យការវាយតម្លៃសក្ខីកម្មរបស់ពួកគេបានពេញលេញ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះទទួលយកឯកសារ E319/42.3.1 និង E319/ 42.3.2 ធ្វើជាឯកសារភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។

៣. អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកបន្ថែមទៀតដល់សេចក្តីសម្រេចរបស់ខ្លួន ឯកសារ E393/1 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦ ដែលអង្គជំនុំជម្រះបានទទួលយកជាភស្តុតាងនូវឯកសារទាំងអស់ដែលជាមូលដ្ឋាននៃបញ្ជីឈ្មោះអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ដែលត្រូវបានបង្កើតដោយ ក.ស.ច.ស (ឯកសារ E393.3)។ ដោយសារ ក.ស.ច.ស ក៏បានសំអាងទៅលើចម្លើយសារភាពរបស់ ចិន សួន នៅមន្ទីរសន្តិសុខ ស-២១ សម្រាប់រៀបចំបញ្ជីឈ្មោះអ្នកជាប់ឃុំដែរនោះ អង្គជំនុំជម្រះយល់ឃើញថា មូលហេតុនៅក្នុងឯកសារ E393/1 ក៏អនុវត្តចំពោះការទទួលយកចម្លើយសារភាពរបស់ ចិន សួន ធ្វើជាភស្តុតាងដែរ ហេតុនេះ អង្គជំនុំជម្រះទទួលយកឯកសារ E319/42/2.1 ធ្វើជាឯកសារភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។

៤. អង្គជំនុំជម្រះសាលាដំបូងដាក់លេខឯកសារ E3/10607 និង E3/10608 ចំពោះឯកសារ

E319/42.3.1 និង E319/42.3.2 និង ដាក់លេខឯកសារ E3/10609 ចំពោះចម្លើយសារភាពរបស់ ចិន ស្លួន (ឯកសារ E319/42/2.1)។

៥. អនុស្សរណៈនេះជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E319/42/2។